Minnesota Department of Health • ព័ត៌មានការពិតអំពីប្រធានបទ     10/11/2005

# Plague

## តើអ្វីជារោគផ្តេក?

ផ្តេក ជារោគដែលបណ្តាលមកពីបាក់តេរីម្យ៉ាង។ តាមធម្មតា រោគនេះឆ្លងរាលដាលពីសត្វកណ្តុរ រឺស្រដៀងសត្វនេះ ទៅមនុស្ស ដោយសារចៃខាំ។ នៅពេលសតុវត្សទី១៤ ជម្ងឺនេះបានឆ្លងពាសពេញពិភពលោក ៣ដងធំ សំលាប់មនុស្ស១ភាគ៣ទៅ១ភាគ២នៃចំនួនប្រជាជន ដែលនៅកន្លែងរោគនេះកើតឡើង។



*ចៃដែលមានរោគផ្តេក*

សូមអរគុណដល់អនាម័យនិងសភាពរស់ នៅដែលប្រសើរឡើងៗការកើតរោគនេះ វាកម្ររមានណាស់ឥឡូវនេះ។ ក៏ប៉ុន្តែ មានទៅដល់២០០០នាក់ មានជម្ងឺ ដោយរួមទាំង១៥នាក់នៅខាងត្បូងភាគខាងលិចនៃសហរដ្ឋ។

មានរោគផ្តេក៣បែប :

- **ប៊ូបននិកផ្តេក** ជារោគបែបម្យ៉ាងដែលមាននៅតាមធម្មជាតិ ដែលកើតឡើង៧៥-៩៧ភាគរយនៃជម្ងឺ។ រោគសញ្ញា ដែលមកភ្លាមៗ រួមទាំងគ្រុនក្តៅ រងារ ខ្សោយ និងឈឺចុកចាប់ និងហើមក្រពេញ រឺ «បាប់បូ» ។
- **សីបទិកសីមិកផ្តេក** – ក្លាយក្នុងឈាមដែលបណ្តាលមកពីបាក់តេរីផ្តេក – វាមិនសូវមានកើតឡើទេ។ វាកើតឡើងតិចជាង២០ភាគរយ។
- **នូមូនិកផ្តេក** ជាជម្ងឺដ៏ធ្ងន់-ប៉ុន្តែមិនសូវមានទេ។ វាតិចជាង១៤ភាគរយនៃអ្នកអ្នកជម្ងឺផ្តែក។ ក៏ប៉ុន្តែ រោគនេះគេបានជឿថា រោគនេះជាលិទ្ធផលដែលពួក ភារិរះជននឹងប្រើក្នុងការវាយប្រហារ។ ជម្ងឺនេះកើតមានឡើងនៅពេលបាក់តេរីចូលក្នុងសួត ដែលបណ្តាលឲ្យមានទឹកក្នុងសួតយ៉ាងឆាប់រហ័សហើយធ្ងន់។

  រោគសញ្ញានៃរោគទឹកក្នុងសួតផ្តេក មានគ្រុនក្តៅខ្លាំង ឈឺដើមទ្រូង ក្អក ដកដង្ហើមផុតៗ ក្អកធ្លាក់ទឹកលាយឈាម រឺសំបោរ។ ប្រសិនបើមិនចាប់ផ្តើមព្យាបាលនឹងថ្នាំផ្សះក្នុងរវាង២៤ម៉ោងទេ អ្នកជម្ងឺនេះ អាចស្លះហើយស្លាប់លឿន។ សំរាប់អ្នកជម្ងឺដែលមិនបានទទួលការព្យាបាលភ្លាមទេនោះ ល្បឿននៃការស្លាប់វាជិត ១០០ ភាគរយ។

  រោគសញ្ញានៃរោគផ្តេកទឹកក្នុងសួត ធម្មតាកើតមានឡើងក្នុងរវាង ១ថ្ងៃទៅ២ថ្ងៃ បន្ទាប់ពីបានឆ្លងបាក់តេរីនេះ។

## តើអ្នកឆ្លងជម្ងឺផ្តេកតាមបៀបណា?

មនុស្សឆ្លងរោគ*ប៊ូបននិក*ផ្តេក តាមរយះសត្វដែលមានជំងឺ។ បាក់តេរីឆ្លងដោយសារចៃដែលមានរោគនេះខាំ ការខាំ រឺកកិតរលាត់ស្បែកដោយសារសត្វដែលមានរោគ រឺបានប៉ះពាល់សត្វងាប់ស្អុយដែលមានរោគ។

មនុស្សឆ្លងរោគ*នូមូនិក*ផ្តេកដោយសារដកដង្ហើមខ្យល់អាកាសមានទឹកដែលមានបាក់តេរីផ្តេក។ ចំហាយទឹកត្រូវបានបញ្ចេញទៅក្នុងខ្យល់អាកាសនៅ ពេលមនុស្សដែលមានរោគ រឺសត្វមានរោគ ក្អក។ ក៏ប៉ុន្តែ ប្រសិនបើ រោគផ្តេកបានយកមកប្រើជាអាវុធវិញ បាក់តេរីបានត្រូវបញ្ចេញទៅក្នុងខ្យល់អាកាស ដោយការប៉ុនប៉ង។

## តើអាចឲ្យអ្នកឆ្លងជម្ងឺនេះពីមនុស្សឯទៀតបានរឺទេ?

មែនហើយ មនុស្សឆ្លងរោគនេះ ដោយដកដង្ហើមចូលចំហាយទឹក នៅពេលមនុស្សដែលមានរោគនោះ ក្អក។

## តើហេតុអ្វីបានជាគេគឹតថា ជម្ងឺនេះអាចយកមកប្រើជាអាវុធដ៏ឃោរឃៅបាន?

ការយកមកប្រើរោគផ្តេកជាអាវុធ បានត្រូវបានសិក្សា យ៉ាងតិចណាស់ ៦០ឆ្នាំ។ គេបានរាយការណ៍ថា ពួកជប៉ុនបានសាកប្រើគ្រាប់បែកមានចំហាយទឹកនៅសង្គ្រាមលោកលើកទី២ ដើម្បីឲ្យចៃមានរោគនោះរាតដ្បាតពាសពេញ។ ប្រទេសសហរដ្ឋនិងសហភាពសូវៀតដើម បានបង្កើតឡើងនូវវិធីផ្សេងៗសំរាប់បញ្ចេញបាក់តេរីទៅក្នុងខ្យល់អាកាស នៅក្នុងឆ្នាំ ១៩៥០ និងឆ្នាំ១៩៦០។

MINNESOTA MDH DEPARTMENT OF HEALTH
Communications Office
625 North Robert Street/Box 64975
St. Paul, MN 55164-0975
(651) 201-4989
www.health.state.mn.us

ផ្តេកត្រូវបានយកមកគិតប្រើជាអាវុធ ពីព្រោះ :

- បាក់តេរីបានបញ្ចេញទៅក្នុងខ្យល់អាកាស ដែលមានឥទ្ធិពលនឹងធ្វើឲ្យឆ្លងដល់មនុស្សមួយចំនួនធំ។
- បាក់តេរី ដែលបានបញ្ចេញទៅក្នុងខ្យល់អាកាស នឹងបង្កើតឡើងនូវរោគ*ទូមូនិក*ផ្តេក។
- រោគទូមូនិកផ្តេក អាចឆ្លងពីមនុស្សម្នាក់ទៅម្នាក់ទៀត ដែលនាំឲ្យជម្ងឺនេះរាលដាលទៀត។
- ទូមូនិកផ្តេក គឺជាជម្ងឺដ៏ធ្ងន់មួយដែលមានការស្លាប់លឿន។
- អាសន្នរោគទូមូនិកផ្តេក នឹងធ្វើឲ្យមានការភិតភ័យនិងចលាចលដ៏សំបើមមួយ។

សញ្ញាមុនបង្អស់នៃការវាយប្រហាររោគទូមូនិកផ្តេក គឺឃើញមានមនុស្សមានបញ្ហាខាងសួតដ៏ធ្ងន់មួយ ស្វែងរកការព្យាបាល នៅពេល១ទៅ២ថ្ងៃបន្ទាប់ពីការវាយប្រហារ។ នៅពេលមានបញ្ហានោះ បាក់តេរីមិននៅក្នុងខ្យល់អាកាសទៀតទេ។ ប្រសិនបើគ្មានវិធានការណ៏រឹងមាំ និងការព្យាបាលច្បាស់លាស់ទេ មនុស្សដែលបានឆ្លងរោគនេះ នឹងត្រូវស្លាប់។

## តើអាចការពារកុំឲ្យមានជម្ងឺទាំងនេះបានរឺទេ?

គ្មានថ្នាំចាក់ការពារសំរាប់រោគផ្តេកនេះទេ តែមានការប្រឹងប្រែងដើម្បីបង្កើតថ្នាំនោះឡើង។ នៅពេលមនុស្សបានឆ្លងពីមនុស្ស រឺសត្វដែលមានរោគ ថ្នាំផ្សះអាចយកមកប្រើដើម្បីការពារជម្ងឺនេះ ប្រសិនបើការព្យាបាលបានចាប់ផ្តើមភ្លាម។

បាក់តេរីផ្តេកដែលបញ្ចេញទៅក្នុងខ្យល់អាកាស អាចរស់បានច្រើនជាង១ម៉ោង។ បាក់តេរីនេះអាចកំចាត់បានដោយពន្លឺព្រះអាទិត្យ កំដៅ និងស្ងួត។ អ្នកអាចបន្ថយការឆ្លងប្រសិនបើអ្នកដោះចេញនូវសំលៀកបំពាក់ ហើយងូតទឹកផ្កាឈូក នៅក្នុងរយះពេលតិចជាង១ម៉ោងដែលបានឆ្លងភ្លាម។ ក៏ប៉ុន្តែ អ្នកត្រូវតែប្រើថ្នាំផ្សះជាវិធីការពារ។

## តើអាចព្យាបាលជម្ងឺផ្តេកនេះបានរឺទេ?

បែបរោគផ្តេកទាំងអស់ អាចព្យាបាលបានដោយប្រើថ្នាំផ្សះ។ ក៏ប៉ុន្តែ មនុស្សដែលមានឆ្លងរោគទូមូនិកផ្តេក ត្រូវតែព្យាបាលក្នុងរវាង២៤ម៉ោង បន្ទាប់ពីគេបានឃើញមានរោគសញ្ញា។ ប្រសិនបើមិនបានព្យាបាលទេ រោគទូមូនិកផ្តេកតែងតែធ្វើឲ្យមានគ្រោះថ្នាក់ធ្ងន់។

## តើគួរឲ្យខ្ញុំធ្វើអ្វី ប្រសិនបើគឹតថា ខ្ញុំប្រហែលបានឆ្លងជម្ងឺផ្តេកហើយនោះ?

ប្រសិនបើអ្នកបានឆ្លងរោគផ្តេក វាមិនច្បាស់ទេថា អ្នកនឹងដឹង។ ក៏ប៉ុន្តែ ប្រសិនបើអ្នកជឿថាអ្នកបានឆ្លង សូមទាក់ទងជាមួយបណ្ឌិតរបស់អ្នកភ្លាម។ ប្រសិនបើអ្នកមានឃើញកាលះទេសះ រឺសកម្មភាពសង្ស័យ សូមរាយការណ៍ដល់ក្រសួងសមត្ថកិច្ចតំបន់របស់អ្នក។